ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

## គោលការណ៍ណែនាំប្រតិបត្តិ
## ស្តីពី
## ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ននិងអង្គភាពរដ្ឋមិនមែន សុខាភិបាល, បណ្តាច្រកទ្វារចេញ-ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស និងទីកន្លែងអាជីវកម្មផ្សេងទៀត, និងសម្រាប់បុគ្គលឯកជន

ថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០២១

# អារម្ភកថា

គោលការណ៍ណែនាំប្រតិបត្តិស្តីពីការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (COVID-19 Rapid Antigen Test) សម្រាប់គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាច្រកទ្វារចេញ-ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត ត្រូវបានរៀបចំឡើងដោយផ្អែកតាមស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងវត្តមាននៃករណីនាំចូលមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) នៅក្នុងប្រទេសកម្ពុជា។ ដើម្បីរួមចំណែកនៅក្នុងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត គោលការណ៍ណែនាំប្រតិបត្តិនេះ ក៏ត្រូវមានវិសាលភាពអនុវត្តផងដែរចំពោះការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមផ្ទះ ឬជាលក្ខណៈឯកជន។ គោលការណ៍ណែនាំប្រតិបត្តិនេះ នឹងត្រូវយកទៅប្រើប្រាស់ជំនួសឱ្យ "**គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (COVID-19 Rapid Antigen Test) ក្នុងសេវាសុខាភិបាលឯកជនស្របច្បាប់**" ។ ដោយឡែក គោលការណ៍ណែនាំប្រតិបត្តិនេះ មិនមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសុខាភិបាលសាធារណៈ, សេវាថែទាំ និងព្យាបាលជំងឺកូវីដ-១៩ និងសេវាដទៃទៀតដែលពាក់ព័ន្ធនឹងការប្រយុទ្ធជំងឺកូវីដ-១៩ ដែលការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបន្តអនុលោមទៅតាមគោលការណ៍ណែនាំដែលកំពុងនៅជាធរមាន។

ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដារ (SOP) សម្រាប់គ្រប់គ្រងអ្នកដំណើរដែលត្រឡប់ពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានៅតាមច្រកទ្វារចេញ-ចូលប្រទេស ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា រួមជាមួយគោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់ការចម្លងនៃមេរោគកូវីដ-១៩ ជាពិសេសមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) និងមេរោគបំប្លែងខ្លួនថ្មីផ្សេងទៀត ពីក្រៅប្រទេសចូលមកក្នុងសហគមន៍នៃប្រទេសកម្ពុជា។

ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ (គ.អ.ក) ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការចំពោះថ្នាក់ដឹកនាំ និងក្រុមការងារបច្ចេកទេសនៃអនុគណៈកម្មការពាក់ព័ន្ធទាំងអស់ ដែលបានខិតខំរៀបចំនូវគោលការណ៍ណែនាំប្រតិបត្តិដ៏មានសារៈសំខាន់នេះឡើង នៅក្នុងកាលៈទេសៈដែលមានការឆ្លងរាលដាលយ៉ាងខ្លាំងក្លានៃជំងឺកូវីដ-១៩។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាមន្ត្រី បុគ្គលិក និងបុគ្គលពាក់ព័ន្ធទាំងអស់ នឹងប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំប្រតិបត្តិនេះ ហើយក្រុមការងារបច្ចេកទេសនឹងធ្វើបច្ចុប្បន្នភាពឯកសារនេះជាបន្តទៀត តាមការចាំបាច់ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍វិវត្តនៃជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

# បញ្ជីមាតិកា


**១. ទិដ្ឋភាពទូទៅនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ១**

**២. លក្ខខណ្ឌនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ១**

២.១. លក្ខខណ្ឌទាក់ទងនឹងឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ១

២.២. លក្ខខណ្ឌរួមទាក់ទងនឹងការអនុញ្ញាតឱ្យប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ២

**៣. គោលការណ៍នៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ៣**

៣.១. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ទីកន្លែងផ្តល់សេវាសុខាភិបាលឯកជនស្របច្បាប់ ...... ៣

៣.១.១- គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់អ្នកមកពិគ្រោះជំងឺ ...... ៤

៣.១.២- គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ផ្នែកសង្គ្រោះបន្ទាន់ ...... ៥

៣.១.៣- ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ត្រួតពិនិត្យផ្ទៃក្នុងនៅទីកន្លែងធ្វើការ ដើម្បីតាមដាន បង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ...... ៧

៣.២. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត ...... ៧

៣.៣. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមច្រកទ្វារចេញ-ចូលប្រទេស ...... ៩

៣.៤. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាលក្ខណៈឯកជន...... ១០

**៤. យន្តការបន្ទាប់ពីការទទួលបានលទ្ធផលនៃការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ...... ១១**

ឧបសម្ព័ន្ធទី១៖ ការធ្វើតេស្តរហ័ស SARS-CoV-2 Rapid Antigen Test របស់ក្រុមហ៊ុន Roche

ឧបសម្ព័ន្ធទី២៖ ការធ្វើតេស្តរហ័ស PANBIO™ COVID-19 Ag RAPID TEST DEVICE របស់ក្រុមហ៊ុន Abbott

ឧបសម្ព័ន្ធទី៣៖ ការធ្វើតេស្តរហ័ស STANDARD Q COVID-19 Ag Test របស់ក្រុមហ៊ុន SD Biosensor

ឧបសម្ព័ន្ធទី៤៖ ការធ្វើតេស្តរហ័ស SARS-CoV-2 Antigen Test by INDICAID របស់ក្រុមហ៊ុន Phase Scientific

ឧបសម្ព័ន្ធទី៥៖ ទម្រង់ស្នើសុំធ្វើពិសោធន៍

## ១. ទិដ្ឋភាពទូទៅនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលកំពុងដាក់ឱ្យប្រើប្រាស់នៅលើពិភពលោក រួមទាំងឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលប្រើប្រាស់នៅកម្ពុជា សុទ្ធតែមានចំណុចខ្សោយមួយ គឺមានករណី "False Negative" ដែលមានន័យថា មានអ្នកផ្ទុកមេរោគកូវីដ-១៩ មួយចំនួនតូច ដែលឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ រកមិនឃើញ ហើយចេញលទ្ធផលអវិជ្ជមានទៅវិញ។ ទោះបីជាយ៉ាងណាក៏ដោយ ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ទាំងនោះ គឺជាឧបករណ៍យុទ្ធសាស្ត្រដែលអាចជួយកាត់ផ្តាច់ខ្សែបណ្តាញចម្លងនៃជំងឺកូវីដ-១៩ ព្រមទាំងមានអត្ថប្រយោជន៍ច្រើន ដើម្បីរួមចំណែកដល់ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាអាទិ៍ មានភាពងាយស្រួលក្នុងការប្រើប្រាស់ដោយមិនតម្រូវឱ្យឆ្លងកាត់មន្ទីរពិសោធន៍, មានតម្លៃសមរម្យដែលអាចប្រើប្រាស់បានទូលំទូលាយ និងមានសមត្ថភាពខ្ពស់ក្នុងការរកឃើញបានឆាប់រហ័សនូវមេរោគកូវីដ-១៩ ជាពិសេស នៅពេលដែលអ្នកផ្ទុកមេរោគនេះ កំពុងចេញរោគសញ្ញា ឬនៅពេលដែលចំនួនមេរោគកូវីដ-១៩ ដែលផ្ទុកក្នុងខ្លួនកើនឡើងខ្ពស់។ ដូច្នេះការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលត្រឹមត្រូវ នឹងជួយពន្លឿនការរកមេរោគកូវីដ-១៩ បាននៅក្នុងស្ថានភាពចាំបាច់។

## ២. លក្ខខណ្ឌនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

### ២.១. លក្ខខណ្ឌទាក់ទងនឹងឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

ក្រសួងសុខាភិបាល ជាស្ថាប័នមានសមត្ថកិច្ចក្នុងការសម្រេចទទួលស្គាល់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងធានាមិនឱ្យមានការនាំចូលផ្តាច់មុខនូវឧបករណ៍តេស្តរហ័សនេះទេ ព្រមទាំងធានាផ្គត់ផ្គង់ឧបករណ៍តេស្តរហ័សឱ្យបានគ្រប់គ្រាន់ទៅតាមបណ្តារាជធានី-ខេត្ត ជាពិសេស ច្រកទ្វារចេញ-ចូលប្រទេសនៅតាមបណ្តាខេត្តជាប់ព្រំដែន។ មានតែឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលត្រូវបានទទួលស្គាល់ដោយក្រសួង-សុខាភិបាល ប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលលទ្ធផលចេញពីការប្រើឧបករណ៍តេស្តរហ័សនេះ ត្រូវបានទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាល។

គិតត្រឹមថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ នេះ ក្រសួងសុខាភិបាលបានផ្តល់ការទទួលស្គាល់ និងអនុញ្ញាតឱ្យប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំនួន ៤ ប្រភេទ ដូចខាងក្រោម៖

១. ABBOTT PANBIO™ COVID-19 Ag RAPID TEST DEVICE

២. ROCHE SARS-CoV-2 Rapid Antigen Test 25T

៣. STANDARD Q COVID-19 Ag Test

៤. INDICAID COVID-19 Rapid Antigen Test។

បន្ថែមលើប្រភេទឧបករណ៍តេស្តរហ័សទាំង ៤ ខាងលើ, ក្រសួងសុខាភិបាល នឹងសិក្សាលើឧបករណ៍តេស្តរហ័សផ្សេងទៀត ដើម្បីផ្តល់ការទទួលស្គាល់ និងការអនុញ្ញាតឱ្យមានការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រ

កម្ពុជា ដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាពខ្ពស់, សុវត្ថិភាពនិងភាពងាយស្រួលក្នុងការប្រើប្រាស់, ភាពឆាប់រហ័សនៃការរកឃើញលទ្ធផល និងថ្លៃទាបសមរម្យ។

គោលការណ៍ណែនាំប្រតិបត្តិនេះ ក៏មានវិសាលភាពអនុវត្តចំពោះឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដែលនឹងត្រូវទទួលស្គាល់នាពេលអនាគត ដោយក្រសួងសុខាភិបាលផងដែរ។

## ២.២. លក្ខខណ្ឌរួមទាក់ទងនឹងការអនុញ្ញាតឱ្យប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

គ្រឹះស្ថានសុខាភិបាលឯកជន, ស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, បណ្តាច្រកទ្វារចេញ-ចូលប្រទេស, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយត្រូវអនុវត្តតាមគោលការណ៍ណែនាំប្រតិបត្តិនេះ។ ដោយឡែក គោលការណ៍ណែនាំប្រតិបត្តិនេះ មិនមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសុខាភិបាលសាធារណៈ, សេវាថែទាំ និងព្យាបាលជំងឺកូវីដ-១៩ និងសេវាដទៃទៀតដែលពាក់ព័ន្ធនឹងការប្រយុទ្ធជំងឺកូវីដ-១៩ ដែលការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបន្តអនុលោមទៅតាមគោលការណ៍ណែនាំដែលកំពុងនៅជាធរមាន។

ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់៖ (១)-នៅពេលមានការសង្ស័យការចម្លងមេរោគកូវីដ-១៩ ដើម្បីជាវិធានការតាមដាន បង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង (២)-នៅពេលមានការផ្ទុះឆ្លងរាលដាននៃជំងឺកូវីដ-១៩ ដើម្បីជាវិធានការស្រាវជ្រាវ និងរុករកអ្នកមានវិជ្ជមានមេរោគកូវីដ-១៩ ដទៃទៀត តាមរយៈការពាក់ព័ន្ធដោយផ្ទាល់ ឬពាក់ព័ន្ធដោយប្រយោល។ ដោយឡែក ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នេះ នឹងត្រូវប្រើប្រាស់នៅតាមបណ្តាច្រកទ្វារចេញ-ចូលប្រទេស ដើម្បីជាមធ្យោបាយក្នុងការរកឃើញឱ្យបានឆាប់រហ័សនូវបុគ្គលដែលផ្ទុកមេរោគកូវីដ-១៩ សំដៅទប់ស្កាត់ និងគ្រប់គ្រងឱ្យបានទាន់ពេលវេលានូវការនាំចូលមេរោគកូវីដ-១៩ ជាពិសេស មេរោគប្រភេទដែលតា (Delta) និងមេរោគបំប្លែងខ្លួនថ្មីប្រភេទផ្សេងទៀត។

ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ក៏ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់នៅតាមផ្ទះ ឬជាលក្ខណៈឯកជន ប៉ុន្តែត្រូវគោរពលក្ខខណ្ឌសុវត្ថិភាព និងការណែនាំចាំបាច់នានា ដែលមានចែងនៅក្នុងគោលការណ៍ណែនាំប្រតិបត្តិនេះ។

វិធីសាស្ត្រនៃការប្រើប្រាស់ និងការគ្រប់គ្រងកាកសំណល់របស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវធ្វើទៅតាមការណែនាំដែលភ្ជាប់ជាមួយឧបករណ៍តេស្តរហ័សនីមួយៗ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ សម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព (Infection, Prevention and Control Guideline = IPC Guideline)។

ក្រុមគ្រូពេទ្យ រួមទាំងពេទ្យយោធា ពេទ្យការងារ ពេទ្យស្ម័គ្រចិត្ត និងគ្រូពេទ្យប្រចាំរោងចក្រ-សហគ្រាស ដែលចុះបញ្ជីក្នុងប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារ (Occupational Safety and Health Network = OSH-NET) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកទទួលបន្ទុកធ្វើតេស្តរហ័សនៅតាមស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជន ក៏ដូចជានៅតាមបណ្តាច្រកទ្វារចេញ-ចូលប្រទេស ត្រូវទទួលបានការអនុញ្ញាតឱ្យអនុវត្តការយកសំណាកវិភាគរកមេរោគដោយប្រើប្រាស់ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ប៉ុន្តែ ត្រូវទទួលបានការបណ្តុះបណ្តាលជាមុនអំពីរបៀបប្រើប្រាស់តេស្តរហ័សនេះ និងការគ្រប់គ្រងកាកសំណល់ដោយសុវត្ថិភាព ដោយមន្ត្រីសុខាភិបាល ឬតាមរយៈការអប់រំបណ្តុះ-បណ្តាលដែលផ្សព្វផ្សាយជាសាធារណៈ ពីសំណាក់ក្រសួងសុខាភិបាល។

នៅទីតាំងតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩, ស្ថាប័ន និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវរៀបចំឱ្យមានទីកន្លែងដាច់ដោយឡែកសម្រាប់ការធ្វើតេស្ត, ទីកន្លែងដាច់ដោយឡែកសម្រាប់ការរង់ចាំលទ្ធផលនៃការធ្វើតេស្ត និងទីកន្លែងដាច់ដោយឡែកសម្រាប់អ្នកដែលត្រូវបានរកឃើញថាមានវិជ្ជមានមេរោគកូវីដ-១៩ ក្នុងអំឡុងពេលរង់ចាំការបញ្ជូនទៅទីកន្លែងព្យាបាល។

## ៣. គោលការណ៍នៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

### ៣.១. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ទីកន្លែងផ្តល់សេវាសុខាភិបាលឯកជនស្របច្បាប់

ឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ទីកន្លែងផ្តល់សេវាសុខាភិបាលឯកជនស្របច្បាប់ ដែលរួមមានមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងសម្ភព ព្រមទាំងគ្រឹះស្ថានសុខាភិបាលឯកជនផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល។ គ្រឹះស្ថានសុខាភិបាលឯកជនត្រូវអនុវត្តតាមលក្ខខណ្ឌដោយឡែក ក្នុងការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដូចខាងក្រោម៖

- ត្រូវមានបុគ្គលិកសុខាភិបាលដែលទទួលបានការបណ្តុះបណ្តាលអំពីការយកសំណាកធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងមានទីតាំងយកសំណាកសមរម្យ
- អាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ CamLIS ឬទម្រង់ស្នើសុំពិសោធន៍ (តេស្តកូវីដ-១៩) របស់ក្រសួងសុខាភិបាល
- ត្រូវគោរពតាមគោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាល និងថែទាំសុខភាព (IPC Guideline)
- ត្រូវធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្ត និងមានការយល់ព្រមពីសាមីខ្លួន

- ត្រូវមានតារាងតម្លៃធ្វើតេស្តរហ័សសមរម្យដែលអាចទទួលយកបាន និងដាក់បង្ហាញជាសាធារណៈនៅគ្រឹះស្ថានសុខាភិបាលឯកជនរបស់ខ្លួន
- ត្រូវបង្ហាញលទ្ធផលវិជ្ជមាន ឬអវិជ្ជមានលើឧបករណ៍តេស្តរហ័ស ដែលមានចុះលេខកូដ ឬឈ្មោះដល់សាមីខ្លួន ដើម្បីផ្ទៀងផ្ទាត់ និងថតរូបទុកជាឯកសារ និង
- ក្នុងករណីរកឃើញអ្នកមានវិជ្ជមានមេរោគកូវីដ-១៩ ត្រូវជូនដំណឹងទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ **១២២២** សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល តាមរយៈការបញ្ជូនអ្នកផ្ទុកមេរោគកូវីដ-១៩ នោះទៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធដោយមន្ត្រីសុខាភិបាល។ ចំពោះខ្សែទូរស័ព្ទ (Hotline) សម្រាប់ភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ ក្រសួងសុខាភិបាលនឹងជូនដំណឹងនៅពេលក្រោយ។

### ៣.១.១- គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់អ្នកមកពិគ្រោះជំងឺ

នៅពេលដែលមានផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍, ប្រជាជនមួយចំនួនអាចឆ្លងជំងឺកូវីដ-១៩ ដោយមិនដឹងខ្លួន។ បុគ្គលដែលមានបញ្ហាសុខភាព នឹងស្វែងរកការពិគ្រោះជំងឺនៅតាមគ្រឹះស្ថានសុខភាពសាធារណៈ ឬមូលដ្ឋានសុខាភិបាលឯកជនស្របច្បាប់។ ក្នុងករណីនេះ អ្នកផ្តល់សេវាសុខាភិបាល ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ទៅលើបុគ្គលដែលមានចេញរោគសញ្ញាជំងឺកូវីដ-១៩ (ដូចជា មានកម្តៅយ៉ាងតិច ៣៧.៥ អង្សាសេ ឬមានរោគសញ្ញាផ្សេងទៀតដូចជា ក្អក ហៀរសំបោរ ឈឺបំពង់ក ហត់ពិបាកដកដង្ហើម) ឬបុគ្គលប៉ះពាល់នឹងអ្នកជំងឺកូវីដ-១៩ ឬបុគ្គលដែលមានការសង្ស័យថាមានការពាក់ព័ន្ធនឹងអ្នកជំងឺកូវីដ-១៩។ ការធ្វើតេស្តនេះក៏អាចធ្វើទៅលើគ្រប់បុគ្គលដែលទៅទទួលសេវាសុខាភិបាល ដោយយោងតាមតម្រូវការចាំបាច់ និងតាមគោលការណ៍កំណត់របស់គ្រឹះស្ថានសុខាភិបាលឯកជននោះ។

ប្រសិនជាលទ្ធផលវិជ្ជមាន ត្រូវដាក់អ្នកមានផ្ទុកមេរោគកូវីដ-១៩ ឱ្យនៅដាច់ដោយឡែកពីគេ ព្រមទាំងជូនដំណឹងទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ **១២២២** សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល តាមរយៈការបញ្ជូនអ្នកផ្ទុកមេរោគកូវីដ-១៩ នោះទៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធ ដោយមន្ត្រីសុខាភិបាល។ ចំពោះខ្សែទូរស័ព្ទ (Hotline) សម្រាប់ភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ ក្រសួងសុខាភិបាល នឹងជូនដំណឹងនៅពេលក្រោយ។

ប្រសិនជាលទ្ធផលអវិជ្ជមាន បុគ្គលដែលទៅទទួលសេវាសុខាភិបាល អាចទទួលបានការព្យាបាល ទោះបីជាគាត់មានរោគសញ្ញាជំងឺកូវីដ-១៩ ក៏ដោយ ប៉ុន្តែ មន្ត្រីសុខាភិបាលត្រូវប្រុងប្រយ័ត្ន និងគោរពតាមគោលការណ៍ណែនាំស្តីពីការបង្ការការឆ្លងមេរោគនៅក្នុងមន្ទីរពេទ្យ។




រូបភាពទី១៖ គំនូសបំព្រួញនៃការប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះអ្នកមកពិគ្រោះជំងឺ

### ៣.១.២- គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ផ្នែកសង្គ្រោះបន្ទាន់

អ្នកជំងឺដែលបញ្ជូនមកផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យ អាចបណ្តាលមកពីជំងឺគ្រប់ប្រភេទ ហើយសុទ្ធតែអាចប៉ះពាល់ដល់ជីវិតរបស់អ្នកជំងឺ។ ការធ្វើតេស្តរកមេរោគកូវីដ-១៩ ដោយប្រើប្រាស់បច្ចេកទេស PCR ត្រូវការពេលយូរដែលអាចបណ្តាលឱ្យហួសពេលក្នុងការជួយសង្គ្រោះអ្នកជំងឺ ដូច្នេះ អ្នកផ្តល់សេវាអាចប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩។

សម្រាប់អ្នកជំងឺសង្គ្រោះបន្ទាន់ ដែលមានរោគសញ្ញារលាកផ្លូវដង្ហើម អ្នកផ្តល់សេវាអាចប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ហើយបើលទ្ធផលវិជ្ជមាន ត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ក្នុងស្ថានភាពសមស្របសម្រាប់អ្នកជំងឺកូវីដ-១៩ និងព្យាបាលនៅកន្លែងដាច់ដោយឡែកក្នុងមន្ទីរពេទ្យ។ បើលទ្ធផលអវិជ្ជមាន អ្នកផ្តល់សេវាត្រូវផ្តល់

សេវាសង្គ្រោះបន្ទាន់ដោយមានការប្រុងប្រយ័ត្ន និងត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ឡើងវិញ ដោយប្រើឧបករណ៍តេស្តរហ័សប្រភេទដូចគ្នា ឬខុសគ្នា ដែលត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយការធ្វើតេស្តរហ័សនេះ ត្រូវធ្វើឡើងដោយបុគ្គលផ្សេងគ្នា (បើអាច) និងដោយមានគម្លាតពីគ្នា ១ ម៉ោង ឬតាមការចាំបាច់។

សម្រាប់អ្នកជំងឺសង្គ្រោះបន្ទាន់ ដែលគ្មានរោគសញ្ញារលាកផ្លូវដង្ហើម អ្នកផ្តល់សេវាអាចប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ហើយបើលទ្ធផលវិជ្ជមាន ត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ក្នុងស្ថានភាពសមស្របសម្រាប់អ្នកជំងឺកូវីដ-១៩ និងព្យាបាលនៅកន្លែងដាច់ដោយឡែកក្នុងមន្ទីរពេទ្យ។ បើលទ្ធផលអវិជ្ជមាន អ្នកផ្តល់សេវាត្រូវផ្តល់សេវាសង្គ្រោះបន្ទាន់ធម្មតា និងដោយមានការប្រុងប្រយ័ត្ន។

ខណៈដែលការផ្តល់សេវាសង្គ្រោះបន្ទាន់ មានភាពចាំបាច់និងបន្ទាន់ក្នុងការសង្គ្រោះជីវិត, ការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាកិច្ចការចាំបាច់ ប៉ុន្តែអាចធ្វើបានបន្ទាប់ពីការសង្គ្រោះបន្ទាន់។ ក្នុងន័យនេះ គ្រូពេទ្យទាំងអស់នៅផ្នែកសង្គ្រោះបន្ទាន់ ត្រូវពាក់ឧបករណ៍ការពារខ្លួន (Personal Protection Equipment = PPE) យ៉ាងហោចណាស់ក្នុងកម្រិតទី២ ដើម្បីការពារខ្លួនពីការឆ្លងមេរោគកូវីដ-១៩ ក្នុងករណីអ្នកជំងឺសង្គ្រោះបន្ទាន់មានវិជ្ជមានមេរោគកូវីដ-១៩។




រូបភាពទី២៖ គំនូសបំព្រួញនៃការប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះផ្នែកសង្គ្រោះបន្ទាន់

### ៣.១.៣- ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ត្រួតពិនិត្យផ្ទៃក្នុងនៅទីកន្លែងធ្វើការ ដើម្បីតាមដាន បង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

គ្រឹះស្ថានសុខាភិបាលឯកជន គឺជាទីកន្លែងដែលមានអ្នកជំងឺចេញ-ចូលដើម្បីប្រើប្រាស់សេវាសុខាភិបាលជាប្រចាំ។ ក្នុងពេលដែលមានការផ្ទុះឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ បុគ្គលិកដែលបម្រើការងារក្នុងវិស័យនេះ ប្រឈមមុខនឹងហានិភ័យខ្ពស់នៃការជួបផ្ទាល់ជាមួយអ្នកមានវិជ្ជមានកូវីដ-១៩ និងឆ្លងជំងឺនេះពីអ្នកជំងឺ។ ទន្ទឹមនេះ បុគ្គលិកផ្នែកសុខាភិបាលដែលមានផ្ទុកមេរោគនេះ ហើយដែលមិនទទួលបានការធ្វើតេស្តដើម្បីវិភាគរកមេរោគឱ្យបានត្រឹមត្រូវ និងជាប់ជាប្រចាំ ក៏អាចបង្កើតបានជាហានិភ័យនៃការចម្លងជំងឺនេះដល់អ្នកជំងឺ ដែលទៅប្រើប្រាស់សេវាសុខាភិបាលនៅទីកន្លែងរបស់ខ្លួន។ ដូចនេះ បន្ថែមលើវិធានការសុវត្ថិភាពផ្នែកសុខាភិបាល និងការចាក់វ៉ាក់សាំងដើម្បីបង្ការជំងឺកូវីដ-១៩, ការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ទៅលើបុគ្គលិកដែលបម្រើការងារក្នុងគ្រឹះស្ថានសុខាភិបាលឯកជន គឺជាវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស ការប្រើប្រាស់តេស្តរហ័សនេះ គឺជាមធ្យោបាយដ៏ល្អមួយក្នុងការរកឃើញឱ្យបានឆាប់រហ័សនូវមេរោគកូវីដ-១៩ ដើម្បីកាត់ផ្តាច់ការឆ្លងរាលដាលនៃមេរោគនេះ នៅក្នុងគ្រឹះស្ថានសុខាភិបាលឯកជន ព្រមទាំងបង្កើនបាននូវជំនឿទុកចិត្តពីសំណាក់អ្នកប្រើប្រាស់សេវាសុខាភិបាលឯកជននេះ។

គ្រឹះស្ថានសុខាភិបាលឯកជន អាចរៀបចំឱ្យមានការធ្វើតេស្តរហ័សលើបុគ្គលិកបម្រើការរបស់ខ្លួនជាប់ជាប្រចាំ និងត្រូវអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្តនិងការយល់ព្រមពីបុគ្គលិកបម្រើការងាររបស់ខ្លួន។

វិធានផ្នែកសុវត្ថិភាពទាក់ទងនឹងការធ្វើតេស្តរហ័ស ក៏ដូចជាការគ្រប់គ្រងបន្តលើអ្នកដែលត្រូវបានរកឃើញវិជ្ជមានមេរោគកូវីដ-១៩ ត្រូវអនុវត្តដូចគ្នានឹងគោលការណ៍ណែនាំក្នុងចំណុច ៣.១.១ និង ៣.១.២ ខាងលើនេះ។

## ៣.២. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត

បន្ថែមលើការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន ដូចជា ការលាងសម្អាតដៃដោយអាល់កុល ឬជែល អនាម័យផ្លូវដង្ហើម ការវាស់កម្តៅ ការពាក់ម៉ាស់ និងការរក្សាគម្លាតសុវត្ថិភាពបុគ្គលនិងសង្គម ដែលមានភាពចាំបាច់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩, តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដើម្បីជាយន្តការគ្រប់គ្រងផ្ទៃក្នុង ការឃ្លាំមើល តាមដាន ទប់ស្កាត់ និងបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងចំណោមមន្ត្រី បុគ្គលិក ឬកម្មករ-និយោជិតរបស់ខ្លួន ក៏ដូចជាដើម្បីស្វែងរកករណីវិជ្ជមានឱ្យបានបានឆាប់រហ័ស ក្នុងករណីសង្ស័យមានការឆ្លងមេរោគកូវីដ-១៩ នៅទីតាំងទាំងនោះ ព្រមទាំង

ស្វែងរកអ្នកដែលពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល បានទាន់ពេលវេលា និងញែកចេញពីមន្ត្រី បុគ្គលិក ឬកម្មករ-និយោជិត ដែលមិនមានការពាក់ព័ន្ធ ក្នុងគោលបំណងធានានិរន្តរភាពការងារនៅក្នុងបណ្ដាស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជនផងដែរ។

ក្នុងករណីមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងស្ថាប័ន និងអង្គភាពរដ្ឋ និងឯកជន មន្ត្រី បុគ្គលិក ឬកម្មករ-និយោជិត នឹងត្រូវញែកជា ២ ក្រុម ដើម្បីធ្វើការសម្អាត និងពិនិត្យសុខភាព ដូចខាងក្រោម៖

-ក្រុមទី១៖ បុគ្គលដែលមានការសង្ស័យឬមានរោគសញ្ញា ឬបុគ្គលដែលជាប់ពាក់ព័ន្ធផ្ទាល់ជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩ ទោះមានឬគ្មានរោគសញ្ញាក៏ដោយ ត្រូវធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩។

-ក្រុមទី២៖ បុគ្គលដែលជាប់ពាក់ព័ន្ធដោយប្រយោលជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩និងគ្មានរោគសញ្ញា និងបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងអ្នកផ្ទុកមេរោគកូវីដ-១៩ អាចរស់នៅ និងធ្វើការបានជាធម្មតា ដោយត្រូវគោរពតាមវិធានសុវត្ថិភាពផ្នែកសុខាភិបាល។

ចំពោះអ្នកមានវិជ្ជមានកូវីដ-១៩ ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីគេ ហើយស្ថាប័ន អង្គភាពពាក់ព័ន្ធត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ **១២២២** សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល តាមរយៈការបញ្ជូនអ្នកផ្ទុកមេរោគកូវីដ-១៩ នោះទៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធដោយមន្ត្រីសុខាភិបាល។ ចំពោះខ្សែទូរស័ព្ទ (Hotline) សម្រាប់ភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ ក្រសួងសុខាភិបាលនឹងជូនដំណឹងនៅពេលក្រោយ។ ចំពោះអ្នកអវិជ្ជមានកូវីដ-១៩ ត្រូវធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័ក ឬនៅតាមផ្ទះ អាស្រ័យលើការវាយតម្លៃកត្តាពាក់ព័ន្ធ។

វិធានខាងលើនេះ ក៏ត្រូវអនុវត្តផងដែរ នៅពេលស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្ដុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត អនុវត្តការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាលក្ខណៈផ្ទៃក្នុងប្រចាំសប្ដាហ៍ ប្រចាំអឌ្ឍមាស និងប្រចាំខែ លើបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពមានហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ឬលើមុខសញ្ញាដែលមានហានិភ័យ នៅក្នុងប្រព័ន្ធទិន្នន័យឃ្លាំមើលកូវីដ-១៩ នៃប្រព័ន្ធសុវត្ថិភាព និងសុខភាពការងារ (OSH-NET) របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សម្រាប់វិស័យការងារ។




រូបភាពទី៣៖ គំនូសបំព្រួញនៃការប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមស្ថាប័ននិងអង្គភាពរដ្ឋមិនមែនសុខាភិបាល, ក្រុមហ៊ុនឯកជន រោងចក្រ-សហគ្រាស ដោយរួមទាំងកន្លែងស្នាក់នៅប្រមូលផ្តុំនៃការដ្ឋានសំណង់ និងទីកន្លែងអាជីវកម្មផ្សេងទៀត

## ៣.៣. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ នៅតាមច្រកទ្វារចេញ-ចូលប្រទេស

ដោយផ្អែកតាមស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងវត្តមាននៃករណីនាំចូលមកក្នុងប្រទេសកម្ពុជានូវមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta) ក៏ដូចជាមេរោគបំប្លែងខ្លួនថ្មីដាយថាហេតុផ្សេងទៀត ព្រមទាំងដើម្បីបង្ការ និងទប់ស្កាត់ការចម្លងនៃជំងឺកូវីដ-១៩ បំប្លែងខ្លួនថ្មីចូលក្នុងសហគមន៍, ការត្រួតពិនិត្យសុខភាពនិងការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ត្រូវអនុវត្តចំពោះគ្រប់អ្នកដំណើរទាំងអស់ (ទោះមានឬគ្មានរោគសញ្ញា) ដែលចូលមកប្រទេសកម្ពុជា តាមច្រកទ្វារចេញ-ចូលប្រទេស។ ចំពោះអ្នកដំណើរដែលធ្វើដំណើរចូលមកប្រទេសកម្ពុជាតាមច្រកព្រំដែនគោក និងព្រំដែនទឹក និងត្រូវបានគេឃើញថាមានលទ្ធផលអវិជ្ជមានដោយឧបករណ៍តេស្តរហ័ស ត្រូវអនុវត្តការធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កដែលអាជ្ញាធរមូលដ្ឋាន

បានរៀបចំនៅច្រកព្រំដែន ចំណែកឯអ្នកដំណើរដែលត្រូវបានរកឃើញមានលទ្ធផលវិជ្ជមាន ត្រូវបញ្ជូនទៅព្យាបាលនៅមណ្ឌលព្យាបាល ឬមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩។ ដោយឡែក ចំពោះអ្នកដំណើរចូលមកប្រទេសកម្ពុជាតាមច្រកទ្វារចេញ-ចូលប្រទេស តាមផ្លូវអាកាស ត្រូវបន្តអនុវត្តការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ និងតេស្ត RT-PCR។




រូបភាពទី៤៖ គំនូសបំព្រួញនៃការប្រើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះអ្នកដំណើរចូលមកកម្ពុជាតាមច្រកព្រំដែនគោក និងព្រំដែនទឹក

## ៣.៤. គោលការណ៍ណែនាំនៃការប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ជាលក្ខណៈឯកជន

បុគ្គលដែលមានការសង្ស័យថាអាចមានឆ្លងជំងឺកូវីដ-១៩ អាចប្រើប្រាស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ដោយខ្លួនឯង ដោយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមវិធីសាស្ត្រនៃការប្រើប្រាស់ និងការគ្រប់គ្រងកាកសំណល់របស់តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ (ការណែនាំលម្អិតមានភ្ជាប់ជាមួយឧបករណ៍តេស្តរហ័ស

នីមួយៗ) និងត្រូវអនុវត្តតាមគោលការណ៍ណែនាំសុវត្ថិភាពផ្នែកសុខាភិបាល ដើម្បីចៀសវាងការចម្លងមេរោគកូវីដ-១៩ ជាយថាហេតុ។

សាមីខ្លួនដែលបានធ្វើតេស្តរកមេរោគកូវីដ-១៩ ដោយខ្លួនឯង ហើយបានរកឃើញវិជ្ជមានមេរោគកូវីដ-១៩ មានកាតព្វកិច្ចជូនដំណឹងទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ **១២២២** សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល ដើម្បីទទួលបាននូវសេវាព្យាបាលនៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធ ដោយមន្ត្រីសុខាភិបាល។ ចំពោះខ្សែទូរស័ព្ទ (Hotline) សម្រាប់ភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ ក្រសួងសុខាភិបាល នឹងជូនដំណឹងនៅពេលក្រោយ។

## ៤. យន្តការបន្ទាប់ពីការទទួលបានលទ្ធផលនៃការធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩

បន្ទាប់ពីការធ្វើតេស្តរហ័សស្របតាមគោលការណ៍ណែនាំដូចបានកំណត់ខាងលើ និងក្នុងករណីដែលត្រូវបានរកឃើញថាមានវិជ្ជមានមេរោគកូវីដ-១៩, គ្រូពេទ្យ អ្នកទទួលបន្ទុកធ្វើតេស្តរហ័ស អ្នកតំណាងនៃស្ថាប័នឬអង្គភាពពាក់ព័ន្ធ ឬសាមីខ្លួនដែលបានធ្វើតេស្តរកមេរោគកូវីដ-១៩ដោយខ្លួនឯង មានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការជូនដំណឹងជាបន្ទាន់ទៅមន្ត្រីសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ឬទាក់ទងទៅខ្សែទូរស័ព្ទ (Hotline) លេខ **១២២២** សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីអនុវត្តនីតិវិធីបន្តទាក់ទងនឹងការព្យាបាល តាមរយៈការបញ្ជូនអ្នកផ្ទុកមេរោគកូវីដ-១៩ នោះទៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬអនុវត្តគោលការណ៍នៃការព្យាបាលនៅតាមផ្ទះ យោងតាមការវាយតម្លៃកត្តាពាក់ព័ន្ធដោយមន្ត្រីសុខាភិបាល។ ចំពោះខ្សែទូរស័ព្ទ (Hotline) សម្រាប់ភូមិសាស្ត្រក្រៅពីរាជធានីភ្នំពេញ ក្រសួងសុខាភិបាលនឹងជូនដំណឹងនៅពេលក្រោយ។ ដោយឡែក ចំពោះបុគ្គលដែលត្រូវបានរកឃើញថាមានវិជ្ជមានមេរោគកូវីដ-១៩ នៅតាមច្រកចេញ-ចូលព្រំដែន ត្រូវបញ្ជូនទៅកាន់ទីកន្លែងព្យាបាលជំងឺកូវីដ-១៩ ដោយឡែក នៅតាមច្រកព្រំដែននោះ។

ចំពោះបុគ្គលដែលត្រូវបានរកឃើញថាអវិជ្ជមានមេរោគកូវីដ-១៩ និងក្នុងករណីដែលតម្រូវឱ្យធ្វើចត្តាឡីស័កត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងវិធានផ្នែកសុខាភិបាលជាធរមាន។

## ឧបសម្ព័ន្ធទី ១៖ ការធ្វើតេស្តរហ័ស SARS-CoV-2 Rapid Antigen Test របស់ក្រុមហ៊ុន Roche

### ការធ្វើតេស្តរហ័ស SARS-CoV-2 Rapid Antigen Test (ក្រុមហ៊ុន Roche)

1



ប្រើតំបារសំឡីតូចដែលភ្ជាប់មកជាមួយប្រអប់តេស្ត។ ត្បារយកសំណាកពីក្នុងរន្ធច្រមុះ ដោយបង្វិល 3-4 ជុំ រួចដកតំបារសំឡីចេញវិញថ្នមៗ។

2




ដាក់តំបារសំឡីទៅក្នុងទីបបាសហ្វ័រ បង្វិលចុះឡើងឲ្យបានច្រើនជាង ៥ ដង រួចយកតំបារសំឡីចេញ។

3



បិទគម្របទីបបាសហ្វ័រ

4




អង្រួនឲ្យសព្វល្អ រួចច្របាច់ទីបបាសហ្វ័របន្តក់ចូល ចំនួន ៣ តំណក់ទៅក្នុងបន្ទះតេស្ត។

5




អានលទ្ធផលចន្លោះពី 15- 30 នាទី។ មិនត្រូវអានលទ្ធផលលើសពី ៣០នាទី។

6

**អានលទ្ធផលតាមរូបភាពខាងក្រោម៖**




លទ្ធផលវិជ្ជមាន




លទ្ធផលអវិជ្ជមាន




លទ្ធផលមិនអាចកំណត់បាន

# ឧបសម្ព័ន្ធទី ២៖ ការធ្វើតេស្តរហ័ស PANBIO™ COVID-19 Ag RAPID TEST DEVICE របស់ក្រុមហ៊ុន Abbott

## ការធ្វើតេស្តរហ័ស SARS-CoV-2 Rapid Antigen Test (ក្រុមហ៊ុន Abbott)

**1**




បន្តក់សូលុយស្យុងបាសហ្វ័រទៅក្នុងទីប Extraction រហូតដល់ចំនុចខ្សែក្រិតលើទីប (300µl)។

**2**




ប្រើតំបារសំឡីតូចដែលភ្ជាប់មកជាមួយប្រអប់តេស្ត។ ត្បារយកសំណាកពីក្នុងរន្ធច្រមុះ (nasal swab) ជម្រៅប្រហែល ២សម ឬ រហូតដល់គល់ច្រមុះដោយបង្វិល ៥ ជុំពីរន្ធច្រមុះទាំងសងខាង ដោយប្រើតំបារតែមួយ រួចដកចេញវិញថ្នមៗ។

**3**




ដាក់តំបារសំឡីដែលត្បាររួចទៅក្នុងទីប Extraction រួចបង្វិលចុះឡើងឲ្យបានច្រើនជាង ៥ដង រួចច្របាច់ទីបដើម្បីឲ្យទឹកក្នុងតំបារសំឡីស្រក់ចុះអស់ ហើយកាច់តំបារសំឡី រួចបិទគម្របទីប។

**4**




អង្រួនទីប Extraction ឲ្យសព្វល្អ រួចមួលគម្របទីបខាងក្រោមចេញ បន្ទាប់មកច្របាច់ទីបបន្តក់ចូលចំនួន ៥ តំណក់ទៅក្នុងបន្ទះតេស្ត។

**5**



ពិនិត្យលទ្ធផលរយៈពេល 15 នាទី។ មិនត្រូវពិនិត្យលទ្ធផលលើសពី ២០នាទីទេ។

**6**

**ពិនិត្យលទ្ធផលតាមរូបភាពខាងក្រោម៖**





លទ្ធផលវិជ្ជមាន



លទ្ធផលអវិជ្ជមាន





លទ្ធផលមិនអាចកំណត់បាន

រៀបចំដោយ៖ ក្រុមមន្ទីរពិសោធន៍ នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២១

# ឧបសម្ព័ន្ធទី ៣៖ ការធ្វើតេស្តរហ័ស STANDARD Q COVID-19 Ag Test របស់ក្រុមហ៊ុន SD Biosensor

## ការធ្វើតេស្តរហ័ស STANDARD Q COVID-19 Ag Test

1



ប្រើតំបារសំឡីតូចដែលភ្ជាប់មកជាមួយប្រអប់តេស្ត។ ត្បារយកសំណាកពីក្នុងរន្ធច្រមុះឲ្យដល់ហ្សាំង (nasopharyngeal swab) ដោយបង្វិល 3-4 ជុំ រួចដកតំបារសំឡីចេញវិញថ្នមៗ។

2




ដាក់តំបារសំឡីទៅក្នុងទីបបាសហ្វ័រ (Extraction buffer tube) បន្ទាប់មកបង្វិលឲ្យបានច្រើនជាង ៥ដង រួចច្របាច់ទីបបាសហ្វ័រ ដើម្បីឲ្យដំណក់ទឹកស្រក់ចុះពីតំបារសំឡីឲ្យអស់ ទើបដកតំបារសំឡីចេញ ហើយចោលទៅក្នុងធុងសម្រាមឆ្លង។

3



បិទគម្របទីបបាសហ្វ័រ

4




អង្រួនឲ្យសព្វល្អ រួចច្របាច់ទីបបាសហ្វ័របន្តក់ចូល ចំនួន ៣ តំណក់ទៅក្នុងបន្ទះតេស្ត។

5




ពិនិត្យលទ្ធផលចន្លោះពី 15- 30 នាទី។ មិនត្រូវពិនិត្យលទ្ធផលលើសពី ៣០នាទីទេ។




6

**ពិនិត្យលទ្ធផលតាមរូបភាពខាងក្រោម៖**







លទ្ធផលវិជ្ជមាន




លទ្ធផលអវិជ្ជមាន







លទ្ធផលមិនអាចកំណត់បាន

រៀបចំដោយ៖ ក្រុមមន្ទីរពិសោធន៍ នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២១

## វិធីសាស្ត្រធ្វើតេស្តរហ័សរក SARS-CoV-2 Antigen Test by INDICAID

1



យកឧបករណ៍ធ្វើតេស្តចេញពីប្រអប់ហើយរក្សាទុកនៅកន្លែងស្អាតមុននឹងធ្វើតេស្ត។

2




ដាក់អ្នកជំងឺអង្គុយក្នុងទីតាំងត្រឹមត្រូវ។ហែកកញ្ចប់យកដំបាសំឡីចេញ បន្ទាប់មកសិកដំបាសំឡីចូលរន្ធច្រមុះ(Nasal)ម្ខាងដោយថ្នមៗប្រហែល 2.5 cm រហូតដល់ទីតាំងយក បង្វិលវាថ្នមៗចំនួន៥ដង។យកដំបាសំឡីដដែលសិកចូលរន្ធច្រមុះម្ខាងទៀតធ្វើដូចលើកទីមួយ។

3




មួលគំរបដបសូលុយស្យុងបន្ទាប់មកដាក់ដំបារសំឡីចូលហើយបង្វិលវាអោយបាន២០ដង ធានាថាដំបាសំឡីនិងសូលុយស្យុងគឺសព្វល្អដោយពាសជាមួយជញ្ជាំងនៃដប ដកដំបាសំឡីចេញ ហើយចោលក្នុងថង់សំរាមឆ្លង។

4



មួលគំរបដបអោយតឹងណែនល្អ។

5




មួលគំរបផ្នែកខាងលើដោយប្រុងប្រយត្ន័

6




កាន់ដបអោយត្រង់ហើយបន្តក់ចូលទៅក្នុងរន្ធចំនួនពាដំណក់ភ្លាមៗ។

7




អានលទ្ធផលក្នុងរយះពេល ២០ នាទី។កុំអានលទ្ធផលលើពី ២៥នាទី។

8




*National Institute of Public Health/National Public Health Laboratory*

## ឧបសម្ព័ន្ធទី ៥៖ ទម្រង់ស្នើសុំធ្វើពិសោធន៍

# ទម្រង់ស្នើសុំធ្វើពិសោធន៍
# Laboratory Request Form

កំណែថ្ងៃទី ០១ មករា ២០២១
Updated on 01 January 2021

| | | | | |
|---|---|---|---|---|
| គ្រឹះស្ថានសុខាភិបាល: Health Facility : | | | កាលបរិច្ឆេទ Date/日期 | |
| ឈ្មោះអ្នកបំពេញទម្រង់: Completed by : | | | លេខទូរស័ព្ទ Telephone/電話 | |
| បំណងនៃការធ្វើតេស្ត Reasons for testing 測試目的 | ☐សង្ស័យ Suspect/懷疑 ☐រលាកសួត Pneumonia/肺炎 ☐បុគ្គលិកពេទ្យ HCW/医护人员 ☐ពលករ Migrants/劳工 ☐តាមដាន Follow-up/複查<br>☐ផ្សេងទៀត Other/其他____<br>☐ប៉ះពាល់ជាមួយអ្នកជំងឺកូវីដ១៩ ឈ្មោះ:____ Contact with COVID cases /新型冠状病毒密切接触者 | | ប្រភេទការប៉ះពាល់: Type of contact | ☐ផ្ទាល់ Direct ☐មិនផ្ទាល់ Indirect |
| ***ព័ត៌មានអ្នកជំងឺ/Patient information/患者信息*** | | | | |
| ឈ្មោះអ្នកជំងឺ Patient Name/患者姓名 | | | លេខសំគាល់ Patient ID | |
| ភេទ Sex /性别 | ☐ប្រុស Male /男 ☐ស្រី Female / 女 | | អាយុ Age /年齢 | |
| សញ្ជាតិ Nationality /国籍 | | | លេខទូរស័ព្ទ Telephone/電話 | |
| អាសយដ្ឋានបច្ចុប្បន្ន Address /地址 | កន្លែងស្នាក់នៅ………… Residence 住所 លេខផ្ទះ:………… House 家 លេខផ្លូវ………… Street 路号<br>ភូមិ………… Village 乡村 ឃុំ………… Commune 公社 ស្រុក………… District 区 ខេត្ត………… Province 省 | | | |
| រោគសញ្ញាគ្លីនិក Clinical Symptoms 临床症状 | ☐គ្រុនក្តៅ Fever 发烧 ☐ក្អក Cough 咳嗽 ☐ហៀរសំបោរ Runny Nose 流鼻涕 ☐ឈឺបំពង់ក Sore Throat 喉咙痛 ☐ពិបាកដកដង្ហើម Difficulty Breathing 呼吸困难 ☐គ្មាន No symptoms 没有症状 | | | |
| ថ្ងៃចេញរោគសញ្ញា Date of onset /发病日期 | | ធ្លាប់កើតជំងឺកូវីដ-១៩ឬទេ? History of COVID-19 positive? 你曾经有过新冠肺炎病毒吗？ | ☐ទេ No 没有 ☐មាន Yes 有 | ថ្ងៃតេស្ត: Test Date: 检测日期 |
| ប្រវត្តធ្វើដំណើរ Travel history/旅行历史 | ឈ្មោះខេត្ត/ប្រទេស Province/Country 国家名称 | | ថ្ងៃមកដល់ Date of arrival 到达日期 | |
| | លិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណ Passport No /护照号 | | លេខកៅអី Seat No/ 座号 | |
| | រៀបរាប់ប្រទេសដែលបានធ្វើដំណើរក្នុងរយៈពេល ១៤ថ្ងៃ មុនមកដល់កម្ពុជា។ | 1…………2…………<br>3…………4…………<br>5…………6………… | | |
| ***ផ្នែកមន្ទីរពិសោធន៍/Laboratory*** | | | | |
| ទីកន្លែងប្រមូលវត្ថុវិភាគ Place of collection | | | ថ្ងៃយកវត្ថុវិភាគ Date of collection | |
| ប្រភេទវត្ថុវិភាគ Type of specimen | ☐ច្រមុះ Nasopharyngeal ☐បំពង់ក Oropharyngeal ☐ផ្សេងទៀត//Others ………… | | មន្ទីរពិសោធន៍ Laboratory ☐IPC ☐NIPH ☐SRH ☐UHS | |
| វត្ថុវិភាគលើកទី(គូសរង្វង់) N° of Sample (circle) | 1 2 3 4 5 6 7 8 9 10 ……… | | | |
| ឈ្មោះអ្នកប្រមូល Sample collector | | លេខទូរស័ព្ទ Telephone | | |

ហត្ថលេខា / Signature: ……………………………………

# ការបកស្រាយ

## Field definitions

| | | |
|---|---|---|
| 1. | **គ្រឹះស្ថានសុខាភិបាល:** | ឈ្មោះគ្រឹះស្ថានសុខាភិបាលដែលទទួលខុសត្រូវក្នុងការយកសំណាក។ ឧ. ឈ្មោះមន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ មន្ទីរពេទ្យ មណ្ឌលសុខភាព និងនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| 2. | **កាលបរិច្ឆេទ** | កាលបរិច្ឆេទនៃការបំពេញទំរង់។ ត្រូវបំពេញតាមលំដាប់ ថ្ងៃ / ខែ / ឆ្នាំ (dd/mm/yyyy)។ ឧ. 21/01/2020 |
| 3. | **ឈ្មោះអ្នកបំពេញទំរង់:** | ឈ្មោះបុគ្គលិកសុខាភិបាលដែលបំពេញទំរង់ |
| 4. | **លេខទូរស័ព្ទ** | លេខទូរស័ព្ទរបស់បុគ្គលិកសុខាភិបាលដែលបំពេញទំរង់ |
| 5. | **បំណងនៃការធ្វើតេស្ត** | សូមជ្រើសរើសបំណងនៃការធ្វើតេស្តតែមួយគត់ និង ឲ្យបានត្រឹមត្រូវដូចជា:<br>➔ សង្ស័យ: សម្រាប់បុគ្គលដែលមានរោគសញ្ញា និង ប្រវត្តិធ្វើដំណើរត្រូវនិយមន័យរបស់ជំងឺកូវីដ<br>➔ រលាកសួត: សម្រាប់អ្នកជំងឺរលាកសួតដែលកំពុងសម្រាកពេទ្យ<br>➔ បុគ្គលិកពេទ្យ: បុគ្គលសុខាភិបាលដែលត្រូវនិយមន័យសង្ស័យ<br>➔ ពលករ: បុគ្គលចំណាកស្រុកដែលត្រឡប់មកពីក្រៅប្រទេស។ ប្រសិនគាត់មានរោគសញ្ញាសូមបញ្ជាក់ពីរោគសញ្ញារបស់គាត់នៅសំណួរទី 10 និង 11<br>➔ តាមដាន: សម្រាប់បុគ្គលទាំងអស់ត្រូវធ្វើតេស្តលើកចាប់ពីលើ ទី ២ឡើងទៅជាពិសេសសម្រាប់អ្នកជំងឺកូវិដ១៩ អ្នកប៉ះពាល់ ពលករ ឬ ការតាមដានផ្សេងទៀត។<br>➔ អ្នកប៉ះពាល់: អ្នកដែលបានប៉ះពាល់ជាមួយអ្នកជំងឺកូវិដ១៩ និងបញ្ជាក់ពីប្រភេទនៃការបះពាល់ ដែលអាចមាន ផ្ទាល់ ឬ មិនផ្ទាល់<br>➔ យន្តការ ឬប្រព័ន្ធឃ្លាំមើលជំងឺកូវីដ-១៩ (OSH នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) |
| 6. | **ឈ្មោះអ្នកជំងឺ ភេទ អាយុ** | បំពេញឈ្មោះ ភេទ និង អាយុ បុគ្គលដែលអ្នកត្រូវយកសំណាក។ បើអាយុតូចជាងមួយឆ្នាំសូមបញ្ជាក់ជាខែ ឬ ថ្ងៃ |
| 7. | **សញ្ជាតិ** | បំពេញសញ្ជាតិបុគ្គលដែលត្រូវយកសំណាក។ បើមានពីរសូមបំពេញទាំងពីរ |
| 8. | **លេខទូរស័ព្ទ** | សរសេរលេខទូរស័ព្ទដែលអាចទំនាក់ទំនងបានរបស់បុគ្គលដែលត្រូវយកសំណាក។ បើមានពីរសូមបំពេញទាំងពីរ។ ប្រសិនបើគ្មានអាចបំពេញប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀតដូចជា Facebook, Telegram, Skype, line, whatapps, wechat…etc. |
| 9. | **អាស័យដ្ឋានបច្ចុប្បន្ន** | អាស័យដ្ឋានបច្ចុប្បន្នដែលអ្នកជំងឺស្នាក់នៅ ឬ នឹងទៅស្នាក់នៅ។ សូមជៀសវៀងសរសេរតាមលិខិតឆ្លងដែន/អត្តសញ្ញាណប័ណ្ណ |
| 10. | **រោគសញ្ញាគ្លីនិក** | រោគសញ្ញាគ្លីនិករបស់បុគ្គលដែលត្រូវយកសំណាក។ ប្រសិនបើមិនមាន សូមជ្រើសរើសយកពាក្យថា "គ្មាន" |
| 11. | **ថ្ងៃចេញរោគសញ្ញា** | កាលបរិច្ឆេទនៃការចេញរោគសញ្ញាដំបូង។ ត្រូវបំពេញតាមលំដាប់ ថ្ងៃ / ខែ / ឆ្នាំ (dd/mm/yyyy)។ ឧ. 21/01/2020 |
| 12. | **ធ្លាប់កើតជំងឺកូវិដ-១៩ឬទេ** | សាកសួរអ្នកត្រូវធ្វើសំណាកអំពីប្រវត្តិនៃកើតជំងឺកូវីដ ប្រសិនបើគាត់ធ្លាប់កើតសូមជ្រើសរើសយក "មាន" រួចបញ្ជាក់កាលបរិច្ឆេទនៃការធ្វើតេស្តវិជ្ជមានលើកដំបូង។ |
| 13. | **ប្រវត្តិធ្វើដំណើរ** | បញ្ចូលឈ្មោះខេត្ត/តំបន់/ប្រទេស កាលបរិច្ឆេទ ដែលបុគ្គលបានឆ្លងកាត់ក្នុងរយៈពេល ១៤ ថ្ងៃមុន និង លេខលិខិតឆ្លងដែន ឬ អត្តសញ្ញាណប័ណ្ណ។ សម្រាប់អ្នកដំណើរតាមយន្តហោះសូមបញ្ជាក់ពីលេខកៅអីបន្ថែម |
| 14. | **ទីកន្លែងប្រមូលវត្ថុវិភាគ** | ឈ្មោះទីតាំងនៃការប្រមូលសំណាក ដែលអាចជាប្រលានយន្តហោះ មន្ទីរពេទ្យ មណ្ឌលចត្តាឡីស័ក ។ល។ |
| 15. | **ថ្ងៃយកវត្ថុវិភាគ** | កាលបរិច្ឆេទនៃការយកសំណាក។ ត្រូវបំពេញតាមលំដាប់ ថ្ងៃ / ខែ / ឆ្នាំ (dd/mm/yyyy)។<br>ឧ. 21/01/2020 |
| 16. | **ប្រភេទវត្ថុវិភាគ** | បញ្ជាក់ពីប្រភេទសំណាកដែលបានយក ដែលមានដូចជា សំណាកច្រមុះ បំពង់ក សំណាកផ្សេងទៀតដូចជា សំណាកឈាម |
| 17. | **មន្ទីរពិសោធន៍** | បញ្ជាក់ឈ្មោះមន្ទីរពិសោធន៍ដែលនឹងត្រូវបញ្ជូនសំណាកទៅសំរាប់ធ្វើតេស្តដែលមាន IPC, NIPH, SRH (Siem Reap) |
| 18. | **វត្ថុវិភាគលើកទី** | គូសរង្វង់ជុំវិញលេខរៀងចំនួនដងនៃការយកសំណាក។<br>→ សូមគូសលេខ ១ សំរាប់សំណាកដំបូងរបស់បុគ្គល សង្ស័យ រលាកសួត បុគ្គលិកពេទ្យ ពលករ អ្នកប៉ះពាល់<br>→ សូមគូសលេខចាប់ពីលេខ ២ សំរាប់សំណាករបស់បុគ្គលដែលត្រូវយកសំណាកដើម្បីតាមដាន |
| 19. | **ឈ្មោះអ្នកប្រមូល** | ឈ្មោះបុគ្គលិកសុខាភិបាលដែលបានយកសំណាក |
| 20. | **លេខទូរស័ព្ទ** | លេខទូរស័ព្ទបុគ្គលិកសុខាភិបាលដែលបានយកសំណាក |